# សេចក្តីជូនដំណឹងពីការជ្រើសរើស អ្នកហាត់ការ

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលត្រូវបានបង្កើតឡើងដោយក្រុមអ្នកជំនាញអភិវឌ្ឍន៍ជនបទ ហើយត្រូវបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ ដោយក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ១០០២សជណ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៨ មានទីស្នាក់ការកណ្តាលនៅក្នុងខេត្តសៀមរាប។ ដោយសារភាពរីកចម្រើន និងការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង យើងបានធ្វើបច្ចុប្បន្នភាព និងទទួលស្គាល់រចនាសម្ព័ន្ធគ្រប់គ្រងថ្មី ដោយក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ១៥៦៧ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។ បច្ចុប្បន្នអង្គការ មានស្នាក់ការកណ្តាលនៅខេត្តសៀមរាប ហើយបាននិងកំពុងប្រតិបត្តិការនៅក្នុងទូទាំងខេត្តសៀមរាប និងមានការិយាល័យរងនៅក្នុងខេត្តកំពង់ធំ។ អង្គការមានបុគ្គលិកចំនួន ៤៧ នាក់ ស្រី៣៧នាក់។ អង្គការមានចក្ខុវិស័យៈ"**ចង់ឃើញគ្រួសារគោលដៅទាំងឡាយរស់នៅប្រកបដោយភាពពេញបរិបូរណ៍**"។ បេសកកម្មរបស់អង្គការគឺ "**ការចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រក្នុងតំបន់គោលដៅនៃប្រទេសកម្ពុជា និងចូលរួមកែលម្អគុណភាពជីវិតដល់គ្រួសារដែលរស់នៅទីនោះ** ។

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា មានបំណងធ្វើការស្វែងយល់បន្ថែមអំពីតម្រូវការទីផ្សារ និងផលិតផលក្នុងស្រុក ក៏ដូចជាផ្តល់ឱកាសដល់និស្សិតដែលកំពុងសិក្សាអំពីផ្នែកទីផ្សារ ក្នុងការស្វែងយល់លើការអនុវត្តន៍ជាក់ស្តែង បន្ថែមពីលើទ្រឹស្តី និងទទួលបានបទពិសោធន៍ការងារ ក្នុងការអភិវឌ្ឍសមត្ថភាព និងអាជីពនាពេលអនាគត គម្រោងត្រូវការជ្រើសរើសអ្នកហាត់ការចំនួនមួយរូបដែលមានត្រូវមានភារកិច្ច និងលក្ខខណ្ឌដូចខាងក្រោមៈ

- **ភារកិច្ច និងការទទួលខុសត្រូវ**
  - ចូលរួមសកម្មភាពទីផ្សារ ឬ ព្រឹត្តិការណ៍នានាដើម្បីលើកកម្ពស់ការយល់ដឹងនិងផ្សព្វផ្សាយផលិតផល
  - ចូលរួមវិភាគទីផ្សារ និងរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ
  - ធ្វើការជាមួយអ្នកពាក់ព័ន្ធដូចជា ក្រុមផលិត អ្នកប្រមូលទិញ អ្នកផ្គត់ផ្គង់ ជាដើម ដើម្បីដោះស្រាយបញ្ហាទីផ្សារ សកម្មភាពប្រកួតប្រជែង បំពេញតម្រូវការរបស់អតិថិជន និងសក្តានុពលសម្រាប់ផលិតផលនិងសេវាកម្មថ្មីៗ
  - ចូលរួមធ្វើឲ្យសម្រេចបាននូវផែនការទីផ្សារដែលបានកំណត់
  - ជួយក្នុងការរៀបចំករណីសិក្សានៃគំរូផលិតផលប្រកបដោយភាពច្នៃប្រឌិត
- **លក្ខណៈសម្បត្តិ**
  - និស្សិតជំនាញទីផ្សារនៃសាកលវិទ្យាល័យ យ៉ាងហោចណាស់ឆ្នាំទី 2
  - មានជំនាញទំនាក់ទំនងល្អ
  - អាចសរសេរ និងនិយាយភាសាខ្មែរ និងអង់គ្លេសបានល្អ
  - មានឆន្ទះធ្វើការជាក្រុម ភាពស្មោះត្រង់ និងខំប្រឹងធ្វើការងារ
  - មានទំនួលខុសត្រូវ មានសុជីវធម៌ និងគុណធម៌
  - មានផ្នត់គំនិតវិជ្ជមាន និងមានការលើកទឹកចិត្តខ្លួនឯងខ្ពស់
  - ចេះជំនាញរដ្ឋបាលល្អ រួមទាំងជំនាញកុំព្យូទ័រសម្រាប់ការិយាល័យ (MS. PowerPoint, Word, Excel, និងអ៊ីម៉ែល
- **អត្ថប្រយោជន៍**
  - ប្រាក់ឧបត្ថម្ភម្ហូបអាហារ និងការធ្វើដំណើរ ត្រូវបានផ្តល់ជូននៅក្នុងករណីនៃបេសកកម្មនៅមូលដ្ឋាន

- ធានារ៉ាប់រងលើគ្រោះថ្នាក់ការងារ និងសុខភាព
- ឱកាសក្លាយជាបុគ្គលិកអចិន្ត្រៃយ៍
- ទទួលបានបទពិសោធន៍ជាក់ស្តែងក្នុងការលក់និងទីផ្សារនៅក្នុងបរិយាកាសអាជីវកម្មពិតប្រាកដ
- ឱកាសដើម្បីអនុវត្តចំណេះដឹងទ្រឹស្តីដែលទទួលបាននៅក្នុងការសិក្សាផ្សាភ្ជាប់នឹងស្ថានភាពជាក់ស្តែង
- បង្កើនការយល់ដឹងពីការលក់និងយុទ្ធសាស្រ្តទីផ្សារ ជំនាញបច្ចេកទេស ជំនាញទន់ និងសហគ្រិនភាព
- ឱកាសដើម្បីធ្វើអន្តរកម្មជាមួយអ្នកជំនាញនៅក្នុងវិស័យលក់និងទីផ្សារ អ្នកជំនាញនានា និងក្រុមការងារគម្រោង
- វិញ្ញាបនប័ត្រទទួលស្គាល់ដោយអង្គការ

- **សេចក្តីណែនាំអំពីការដាក់ពាក្យ**

  សូមផ្ញើប្រវត្តិរូបសង្ខេប និងលិខិតបញ្ជាក់ផ្សេងៗ មកការិយាល័យរដ្ឋបាល និងគណនេយ្យរបស់អង្គការអ្នកត្រួសត្រាយនៃកម្ពុជា តាមអាសយដ្ឋានដូចខាងក្រោម៖

  - សារអេឡិចត្រូនិច៖ info@tco-cambodia.org ឬ malibopha@tco-cambodia.org
  - ការិយាល័យកណ្តាល ស្ថិតនៅភូមិគោកធ្លក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប
  - សម្រាប់ព័ត៌មានបន្ថែមអាចទំនាក់ទំនងមកលេខ 017 574 200/ 092 444 656
  - កាលបរិច្ឆេទឈប់ទទួលពាក្យ **ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ៥:00នាទីល្ងាច។**